**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ០១ អនក្រ.បក**

# អនុក្រឹត្យ

**ស្តីពី**

**ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៥.០៨០ ហិកតា**

**ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកបរកែវ និងស្រុកអណ្តូងមាស ខេត្តរតនគិរី**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**មាត្រា១:-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៩.០៨០ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកបរកែវ និងស្រុកអណ្តូងមាស ខេត្តរតនគិរី ដើម្បីធ្វើការវិនិយោគដាំកៅស៊ូ ដូចមានក្នុងផែនទី និងនិយាមកាលេខ ១៥៦៤/១០ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១០ របស់សាលាខេត្តរតនគិរី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា២:-**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍ របស់រាជរដ្ឋាភិបាល ។

**មាត្រា៣:-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្តរតនគិរី ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១១

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

ផែនទី ទីតាំងដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ខាសនា អ៊ិនវេសមេន រុក្ខកៅស៊ូ ស្រុកលំផាត់ និង ស្រុកបរកែវ ខេត្តរតនគិរី




ព្រឹត្តិសញ្ញា :

- ទីរួមខេត្ត
- ភូមិ
- ឃុំ
- ស្រុក
- ព្រំប្រទល់ឃុំ
- ព្រំប្រទល់ស្រុក
- ផ្លូវលំ
- ផ្លូវទឹក
- ព្រំដីសម្បទានសេដ្ឋកិច្ច ខាសនា អ៊ិនវេសមេន
- ដីសម្បទានសេដ្ឋកិច្ច
- តំបន់ត្រូវទុកផ្លូវទឹក
- តំបន់ស្នើសុំបង្កើតសហគមន៍ព្រៃឈើ
- តំបន់ភ្នំ

តំបន់ព្រៃឆ្នាំ២០០២

| | |
|---|---|
| ព្រៃស្រោង | ២៧៩ ហ.ត |
| ព្រៃពាក់កណ្តាលស្រោង | ៦ ៨១២ ហ.ត |
| ព្រៃល្បោះ | ៣ ២៣៥ ហ.ត |
| ព្រៃផ្សេងៗ | ១ ៦២៩ ហ.ត |
| ព្រៃឬស្សីលាយ | ១០០ ហ.ត |
| ព្រៃឬស្សីសុទ្ធ | ៤៩ ហ.ត |
| ដីគ្មានគំរបព្រៃ | ១ ៧៨៥ ហ.ត |
| សរុប : | ១៣ ៤៨៩ ហ.ត |

ផ្ទៃដីកាត់ចេញ :

| | |
|---|---|
| ផ្ទៃជាន់ជាមួយក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចក្រុងបុក | ២២ ហ.ត |
| ក្រុមហ៊ុន ហេង ប្រាទើ | ២ ៦៣៣ ហ.ត |
| តំបន់ត្រូវទុកផ្លូវទឹក | ៥៤៣ ហ.ត |
| តំបន់ស្នើសុំបង្កើតសហគមន៍ព្រៃឈើ | ១០៩ ហ.ត |
| តំបន់ភ្នំ | ៦៦១ ហ.ត |
| ដីប្រជាពលរដ្ឋ | ៣ ៧៣៦ ហ.ត |

ផ្ទៃដីកាត់ចេញសរុប: ៨ ៤០៥ ហ.ត

ផ្ទៃ ដី កាត់ ទី សហគមន៍ : ៥ ០៨០ ហ.ត

| ចំនុចនិយាមការសហគមន៍ព្រៃឈើ | | |
|---|---|---|
| N | X | Y |
| 1 | 738744 | 1527167 |
| 2 | 738894 | 1527326 |
| 3 | 738968 | 1527497 |
| 4 | 739283 | 1527547 |
| 5 | 739371 | 1527456 |
| 6 | 789572 | 1527489 |
| 7 | 739984 | 1527087 |
| 8 | 738816 | 1526881 |
| 9 | 738796 | 1526891 |
| 10 | 738772 | 1526862 |
| 11 | 738719 | 1526862 |
| 12 | 738504 | 1526643 |
| 13 | 739377 | 1526461 |
| 14 | 739289 | 1526434 |
| 15 | 739139 | 1526462 |
| 16 | 738980 | 1526475 |
| 17 | 738815 | 1526346 |
| 18 | 738718 | 1526246 |
| 19 | 738485 | 1526213 |
| 20 | 733485 | 1526623 |
| 21 | 738536 | 1526664 |
| 22 | 738629 | 1526964 |
| 23 | 738644 | 1527047 |
| 24 | 738744 | 1527167 |

បានឃើញ និង ឯកភាព

សយ សុណា

ខែ ជាវិរៈ

ហេង ប៊ុនថាន់

ឌឹម ស៊ីណាត

ប៉ាវ ហាមផាន